

# សុខលី និងខ្លែង

Let's Read

The Asia Foundation



សុខលីជាក្មេងដែលរស់នៅក្នុងតំបន់ដាច់ស្រយាល។ ថ្ងៃមួយ ឪពុករបស់ គេបានទិញខ្លែងរាងមេអំបៅ ចម្រុះពណ៌ យ៉ាង ស្រស់ស្អាតឱ្យគេ។ សុខលី សប្បាយចិត្តណាស់ ហើយ ដាក់ឈ្មោះឱ្យវាថា មេអំបៅ។ នៅពេលទំនេរ គេបង្ហោះខ្លែងនោះ លេងគ្រប់ទីកន្លែង ៖ នៅក្បែរផ្ទះតាមផ្លូវ ក្បែរចម្ការ និងតាម ភ្លឺស្រែ។



ល្ងាចមួយ ពេលដែលខ្លែងរបស់សុខលីកំពុងតែហោះនៅលើ
អាកាស ស្រាប់តែមានខ្យល់បក់មកយ៉ាងខ្លាំង។ ធូលីធ្វើឱ្យគេ
មិនអាចមើលឃើញ អ្វីទាំងអស់។ លុះខ្យល់ស្ងប់ទៅ ទើបសុខ
លីដឹងថា មេអំបៅរបស់គេបាន ហើរបាត់ទៅហើយ។ គេដើរយឺត
ៗសម្លឹងមើលព្រះអាទិត្យរៀបលិច ដោយទឹកមុខស្រពោន។
គេពិបាកចិត្តខ្លាំងណាស់ ហើយមិនហ៊ានយក រឿងនេះប្រាប់
ឪពុកម្ដាយទេ។



យប់នេះសុខលីដេកមិនលក់សោះ។ គេស្រមៃឃើញខ្លែងរបស់គេជានិច្ចៈ - មេអំបៅ តើឯងនៅទីណា? តើឯងកំពុងនៅទីក្រុងភ្នំពេញឬ? តើឯងបានឃើញវិមានឯករាជ្យដែរឬទេ? តើឯងនឹងត្រលប់មក ផ្ទះវិញទេ?



សុខលី កុមារដែលបាត់ខ្លែង ប្រែខ្លួនទៅខាងស្ដាំ៖ - មេអំបៅ តើឯងនៅទីណា? តើឯងកំពុងហោះកាត់បឹងទន្លេសាបឬ? តើឯងមានឃើញពពួកត្រីដែរឬទេ? តើឯងនឹងត្រលប់មកផ្ទះវិញទេ?



សុខលី កុមារដែលបាត់ខ្លែង ប្រែខ្លួនទៅខាងឆ្វេង៖ - មេអំបៅ តើឯងនៅទីណា? តើឯងកំពុងនៅសៀមរាបឬ? តើឯងបានឃើញប្រាសាទអង្គរដែរឬទេ? តើឯងនឹងត្រលប់មកផ្ទះវិញទេ?



សុខលី កុមារដែលបាត់ខ្លែង ក្រោកអង្គុយ៖ - មេអំបៅ តើឯង នៅទីណា? តើឯងកំពុងនៅខេត្តរតនគីរីឬ? តើឯងមានឃើញ សត្វដំរី ខ្លា ស្វាដែរឬទេ? តើឯងនឹងត្រលប់មកផ្ទះវិញទេ?



សុខលីនឹកខ្លែងគេកាន់តែខ្លាំង។ គេក្រោកឈរឡើង ហើយដើរទៅមាត់បង្អួចសម្លឹងមើលមេឃ ដែលសម្បូរដោយផ្កាយ៖ -មេអំបៅ តើឯងនៅទីណា? តើឯងចេញផុតពីផែនដីហើយឬ? តើឯងមានឃើញពួកអ្នកវិទ្យាសាស្ត្រ និងយានរបស់គេដែរឬទេ? តើឯងនឹងត្រលប់មកផ្ទះវិញទេ?



សុខលីសម្លឹងមើលមេឃយ៉ាងយូរ គេដកដង្ហើមធំៗ - ខ្ញុំដឹងថា ឯងបានទៅកន្លែងទាំងអស់នោះ។ ឯងមិនត្រលប់មកវិញទេ ព្រោះឯងមិនចូលចិត្តខ្ញុំ និងផ្ទះរបស់ខ្ញុំ។ តែខ្ញុំនៅតែស្រលាញ់ឯង ជានិច្ច។



ព្រឹកនេះ សុខលីភ្ញាក់ពីដេកយឺតជាងរាល់ដង។ គេដើរទៅជួប ឪពុក ម្តាយ ទាំងស្រងូតស្រងាត់។ ឃើញដូច្នោះ ម្តាយរបស់គេ ក៏សួរឡើង៖ - សុខលី កូនមានរឿងអី? សុខលីអង្គុយជិតម្តាយ រួចឆ្លើយទាំងតតាក់តតុប ៖ - ម៉ែ... គឺ... កូនបានធ្វើ...បាត់... មេអំបៅហើយ...



ពេលនោះ ឪពុករបស់សុខលីដើរសំដៅទៅកញ្ច្រែងធំមួយ ដែលនៅលើ គ្រែក្បែរនោះ។ សុខលីឃើញគាត់ទាញមេអំបៅចេញមក។ គាត់និយាយ ទាំងហុចខ្លែងឱ្យកូន៖ - ពុកឃើញវានៅជាប់នឹងមែកអំពិលទឹក កាលពីព្រឹកមិញ។ គេទទួលខ្លែងពីឪពុកទាំងលោតកញ្ឆេង។



ឪពុកម្ដាយមើលមុខកូន ទាំងញញឹម។ ម្ដាយនិយាយបន្ថែម៖ - មេអំបៅរបស់កូនត្រលប់មកវិញ ដោយសារតែវានៅតែស្រលាញ់កូន។



អ្នកទទួលខុសត្រូវបោះពុម្ពផ្សាយ ៖ហុក សុទ្ធិ អ្នកគ្រប់គ្រង
កម្មវិធីបោះពុម្ព ៖ហួត សុជាតា អ្នកបោះពុម្ពផ្សាយ៖ហេង ដារី
និង អ៊ូច សូដានី ជំនួយការបោះពុម្ពផ្សាយ ផ្នែកសៀវភៅកុមារ
តូច៖អ៊ុំវ័ណថារី អ្នករចនាទំព័រ៖ប៉ែន សំបូរណ៍ អ្នកត្រួតពិនិត្យ
អត្ថបទ៖ស៊ុនហេង ម៉េងឈាង និងក្រុមបោះពុម្ពផ្សាយSipar
ការថ្លែងអំណរគុណ អង្គការSipar សូមថ្លែងអំណរគុណ
ចំពោះ ជ្រឹម ហុកស្រិ◌ុន ដែលបានចូលរួមសហការបោះពុម្ព
សៀវភៅនេះលើកទី១។ អង្គការSipar សូមថ្លែងអំណរគុណ
ចំពោះលោកស្រី លី សុវណ្ណា មិត្តភក្តិ និងក្រុមហ៊ុន Comgest
ដែលបានឧបត្ថម្ភដល់ការ បោះពុម្ពសៀវភៅនេះលើកទី១។
©គ្រឹះស្ថានបោះពុម្ពផ្សាយSipar ផ្ទះលេខ9 ផ្លូវ334 ប្រអប់
សំបុត្រ31 ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ 855-23-216 001 /

edition@sipar-cam.org www.sipar-books.com
បោះពុម្ពលើកទី1 ឆ្នាំ 2011 បោះពុម្ពលើកទី4 ឆ្នាំ 2016 រាល់ការចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ទោះបីជាតាមរបៀបណាក៏ដោយ បើគ្មានការយល់ព្រមពី អង្គការSipar គឺខុសច្បាប់ និងត្រូវមានទោស។រក្សាសិទ្ធិចម្លង និងបកប្រែចំពោះគ្រប់ប្រទេសទាំងអស់។ បោះពុម្ពនៅប្រទេសកម្ពុជាដោយរោងពុម្ព S.H Printing House

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*សុខលី និងខ្លែង*, Published by Sipar, © Sipar. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/